ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# មតិសំណេះសំណាល
# លោកជំទាវ ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ក្នុងពិធីសម្ពោធ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សាថ្មី
# វិទ្យាល័យតាំងក្រសាំង
# ថ្ងៃអាទិត្យ ៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
# ត្រូវនឹងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៤ ស្រុកសន្ទុក ខេត្តកំពង់ធំ

**សូមគោរព ៖**

- **លោក Pak Du Ho នាយកប្រតិបត្តិ ធនាគារឯកទេស ខេប៊ី ដេហាន ម.ក**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអាជ្ញាធរដែនដី និងសហការី**
- **លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងពិធីសម្ពោធនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សាថ្មីនៃវិទ្យាល័យតាំងក្រសាំងនេះជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ នៅឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ នាពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខប្រកបដោយក្តីនឹករឭកពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង **ឯកឧត្តម ជា ចាន់តូ** អគ្គទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា ដែលលោកតែងតែគិតគូរពីសុខទុក្ខរបស់ប្រជាជនទាំងអស់នៅទូទាំងប្រទេស ជាពិសេស នៅក្នុងខេត្តកំពង់ធំ។ ក្នុងនាមជាអ្នកបន្តវេនជំនាន់ក្រោយ យើងត្រូវចងចាំជានិច្ច និងដឹងគុណឧបការៈចំពោះថ្នាក់ដឹកនាំទាំងអស់ ដែលបានបន្សល់ទុកនូវស្នាដៃជាច្រើន ដែលនាំមកនូវការអភិវឌ្ឍរីកចម្រើន ជាពិសេស តាមរយៈគោលនយោបាយ ឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានសុខសន្តិភាព មានការអភិវឌ្ឍលើគ្រប់វិស័យ និងមានកិត្តិនាមល្បីរន្ទឺទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ។ ក្នុងនោះ វិស័យអប់រំក៏មានការរីកចម្រើននិងបានដើរតួនាទីស្នូលក្នុងការកសាងធនធានមនុស្ស សម្រាប់រួមចំណែកអភិវឌ្ឍប្រទេសជាតិយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព។

ខ្ញុំសូមអបអរសាទរចំពោះអគារសិក្សាមួយខ្នងនេះ ដែលជាអគារមានកម្ពស់២ជាន់ ស្មើនឹង ១២បន្ទប់ ព្រមទាំងមានបំពាក់គ្រឿងបរិក្ខារតាមបន្ទប់នីមួយៗ ហើយក៏ជាសមិទ្ធផលថ្មីមួយបន្ថែមទៀតសម្រាប់វិទ្យាល័យតាំងក្រសាំងនាពេលនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក

Pak Du Ho ថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងធនាគារឯកទេស ខេប៊ី ដេហាន ម.ក ដែលបានគាំទ្រឧបត្ថម្ភផ្នែកហិរញ្ញវត្ថុក្នុងការកសាងអគារសិក្សានេះឡើង ព្រមទាំងសូមថ្លែងអំណរគុណចំពោះ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មន្ទីរអប់រំយុវជន និងកីឡា លោកនាយក លោកគ្រូ អ្នកគ្រូ និងដៃគូអភិវឌ្ឍនានា ដែលបានផ្ដល់កិច្ចសហប្រតិបត្តិការល្អ និងរួមសាមគ្គីគ្នាកសាងអគារសិក្សាថ្មីនេះឡើងសម្រាប់បម្រើវិស័យអប់រំ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់នៅក្នុងវិទ្យាល័យនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូអ្នកគ្រូ និងក្មួយៗសិស្សានុសិស្ស ជាទីមេត្រី!**

នៅក្នុងយុគសម័យនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ផ្អែកលើមូលដ្ឋានចំណេះដឹង (knowledge based economy) បច្ចុប្បន្ននេះ យុវជនបានដើរតួនាទីយ៉ាងសំខាន់សម្រាប់ប្រទេសជាតិ។ ពាក្យខ្មែរយើងថា "ទំពាំងស្នងឫស្សី" មានន័យថា យុវជនគឺជាកម្លាំងបន្តវេននិងជាធនធានមនុស្សយ៉ាងសំខាន់ និងប្រកបដោយសក្ដានុពលរបស់ស្ថាប័នឬប្រទេសជាតិមួយ សម្រាប់រួមចំណែកក្នុងបុព្វហេតុការពារ កសាង និងអភិវឌ្ឍប្រទេសជាតិរបស់ខ្លួនឱ្យសម្បូររុងរឿង។ បើប្រទេសជាតិណាដែលសម្បូរយុវជន-យុវនារី ដែលមានចំណេះដឹងច្រើន ប្រកបដោយសក្ដានុពល គឺជាប្រភពធនធានសម្បូរបែបសម្រាប់រួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន។

រាជរដ្ឋាភិបាលកម្ពុជាថ្មី ក្រោមការដឹកនាំរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើដំណើរទៅមុខយ៉ាងស្វាហាប់ និងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យសំខាន់ៗនានាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុក ការអភិវឌ្ឍមូលធនមនុស្សជាអាទិភាពទី១ នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដោយផ្ដោតលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ជាក់ស្ដែង **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានផ្ដល់អនុសាសន៍គន្លឹះ ៤ចំណុច សំដៅលើកកម្ពស់គុណភាពអប់រំដោយផ្ដោតសំខាន់លើការពង្រឹងគុណភាពសាលារៀនរដ្ឋ រួមមាន៖ ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា និងទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក "ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ"។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូអ្នកគ្រូ និងក្មួយៗសិស្សានុសិស្ស ជាទីមេត្រី!**

ការអភិវឌ្ឍវិស័យអប់រំឱ្យបានរីកចម្រើនទៅមុខ គឺពឹងផ្អែកលើកត្តាសំខាន់ៗចំនួន ២។ ទី១. កត្តាហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមានផ្លូវថ្នល់ សាលារៀន បណ្ណាល័យ បរិក្ខាសាលា និងសម្ភារសិក្សា ជាដើម។ និងទី២. កត្តាគុណភាពនៃការអប់រំសំដៅលើគុណភាពកម្មវិធីសិក្សា ការពង្រឹងវិន័យសិក្សា និងគ្រូបង្រៀនដែលមានចំណេះដឹងខ្ពស់ផ្នែកឯកទេស និងគរុកោសល្យក្នុងការបង្រៀន។ សមិទ្ធផលអគារសិក្សាថ្មីយើងក្នុងថ្ងៃនេះ គឺបានបង្ហាញពីកត្តាហេដ្ឋារចនាសម្ព័ន្ធនេះតែម្ដង។

យើងគួរតែមានមោទនភាពចំពោះស្រុកសន្ទុកយើង ដែល **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា លោកបានអញ្ជើញចូលរួមសម្ពោធអនុវិទ្យាល័យ ហ៊ុន សែន ប្រាសាទ នៅស្រុកសន្ទុក ក្នុងឆ្នាំ២០០៨ កន្លងមក ហើយសម្ដេចបានមានប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ថា "ឃុំ ១ គួរតែមានអនុវិទ្យាល័យ ១"។ ប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់នេះជាចំណុចចាប់ផ្ដើមនៃការអភិវឌ្ឍ និងការពង្រឹងនៃការធ្វើកំណែទម្រង់វិស័យអប់រំនៅទូទាំងប្រទេស។ ពីមុនសិស្សមានការលំបាកក្នុងការទទួលបានសេវាអប់រំ តែឥឡូវនេះ នៅស្រុកសន្ទុកយើងមានអនុវិទ្យាល័យចំនួន ១ នៅគ្រប់ឃុំទាំងអស់ ដែល

ស្របតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្ដេច ដែលបង្កលក្ខណៈងាយស្រួល និងផ្ដល់ឱកាសឱ្យក្មួយៗសិស្សានុសិស្ស បានបន្តការសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា និងទទួលបានការអប់រំខ្ពស់ ស្របតាមការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចនិងសង្គម។

ចំពោះធនាគារជាតិនៃកម្ពុជា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជានិច្ចកាលយើងបាននិងកំពុងអនុវត្តការងារមួយចំនួនដូចជា៖ ១/- បន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី១២ ២/- សហការអនុវត្តលើអនុស្សរណៈយោគយល់ជាមួយ ក្រសួងកិច្ចការនារី ស្ដីពី "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" ៣/- សហការអនុវត្តយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ" ជាមួយអង្គការ Good Return និង ៤/- បន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅតាមបណ្ដាខេត្ត និងក្រុង/ស្រុកនានា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្ស ជាទីមេត្រី!**

ដើម្បីរួមចំណែកលើកកម្ពស់និងបង្កើនមូលដ្ឋានចំណេះដឹងរបស់ក្មួយៗបន្ថែមទៀត ខ្ញុំសូមឱ្យក្មួយៗសិស្សានុសិស្សត្រូវប្រកាន់ខ្ជាប់នូវព្រះពុទ្ធឱវាទទាំងបួនប្រការ គឺ សុ ចិ បុ លិ។ **សុ** : មានន័យថាត្រូវខិតខំត្រងត្រាប់ស្ដាប់ **ចិ** : ត្រូវចេះគិតគូរពីហេតុផល **បុ** : ត្រូវចេះសួរដេញដោលរកខុសត្រូវ និង **លិ** : ត្រូវចេះ កត់ត្រាទុកនូវអ្វីដែលមានសារៈប្រយោជន៍ចំពោះខ្លួននៅពេលអនាគត។ បុគ្គលទាំងឡាយណាដែលប្រកាន់ខ្ជាប់នូវអង្គទាំងបួនខាងលើនេះ គឺជាបុគ្គលដែលសម្បូរទៅដោយពុទ្ធិក្នុងការគ្រប់គ្រងជីវិត និងដោះស្រាយការងាររបស់ខ្លួនប្រកបដោយជោគជ័យ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅម្ដងទៀតចំពោះ ថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងធនាគារឯកទេស ខេប៊ី ដេហាន ម.ក ដែលបានផ្ដួចផ្ដើមក្នុងការកសាងអគារសិក្សានេះឡើង។ ខ្ញុំសូមអំពាវនាវឱ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាជ្ញាធរមានសមត្ថកិច្ច មាតាបិតា និងអាណាព្យាបាលសិស្សទាំងអស់ សូមមេត្តាជួយថែរក្សាអគារសិក្សានេះ ឱ្យបានគង់វង្សជាប្រយោជន៍ ដើម្បីប្រើប្រាស់សមិទ្ធផលទាំងនេះឱ្យបានយូរអង្វែងសម្រាប់កូនចៅជំនាន់ក្រោយរបស់យើងតរៀងទៅ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូន លោកគ្រូ អ្នកគ្រូ មាតា បិតា ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ឱ្យបានជ្រាបថា ដើម្បីចូលរួមចំណែកលើកកម្ពស់ការអប់រំ និងអភិវឌ្ឍធនធានមនុស្ស ធនាគារជាតិនៃកម្ពុជានឹងមានឧបត្ថម្ភវគ្គរៀនបំប៉នជូនសិស្សថ្នាក់ទី១២ នៅក្នុងស្រុកសន្ទុក និងផ្ដល់អាហារូបករណ៍ជូនសិស្សនិទ្ទេស A ឱ្យបានសិក្សានៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ។

ទន្ទឹមនេះ ថ្ងៃនេះខ្ញុំ តំណាងធនាគារជាតិនៃកម្ពុជា ក៏បាននាំយកនូវអំណោយ និងប្រាក់ឧបត្ថម្ភ ដើម្បីចែកជូនបងប្អូនប្រជាពលរដ្ឋយើងសរុបប្រមាណ ៨៥៧នាក់ ដែលក្នុងនោះរួមមាន៖

១/- ប្រាក់ឧបត្ថម្ភរៀបចំកម្មវិធី ចំនួន ៣.០០០.០០០រៀល

២/- ឧបត្ថម្ភជូន នាយក នាយករង លោកគ្រូ និងអ្នកគ្រូ ចំនួន៨៥នាក់ ក្នុងម្នាក់ទទួលបាន សារុង១ និងថវិកា ៥០.០០០រៀល

៣/- ឧបត្ថម្ភជូន ក្រុមប្រឹក្សាឃុំ និងភូមិតាំងក្រសាំង ចំនួន២២នាក់ ក្នុងម្នាក់ទទួលបានសារុង១ និងថវិកា ៥០.០០០រៀល

៤/- ឧបត្ថម្ភជូន ស.ស.យ.ក ចំនួន៥០នាក់ ក្នុងម្នាក់ទទួលបានសារុង១ និងថវិកា ៥០.០០០រៀល

៥/- ឧបត្ថម្ភជូន យុវជនកាកបាទក្រហម ចំនួន៥០នាក់ ក្នុងម្នាក់ទទួលបានសៀវភៅ២ក្បាល ប៊ិក២ដើម ខ្មៅដៃ១ដើម និងថវិកា ១០.០០០រៀល

៦/- ឧបត្ថម្ភជូន សិស្សកាយរឹទ្ធ ចំនួន៥០នាក់ ក្នុងម្នាក់ទទួលបានសៀវភៅ២ក្បាល ប៊ិក២ដើម ខ្មៅដៃ១ដើម និងថវិកា ១០.០០០រៀល

៧/- ឧបត្ថម្ភជូន សិស្សានុសិស្ស (ថ្នាក់ទី៩-១០-១១-១២) ចំនួន២៥០នាក់ ក្នុងម្នាក់ទទួលបានសៀវភៅ២ក្បាល ប៊ិក២ដើម ខ្មៅដៃ១ដើម និងថវិកា ១០.០០០រៀល និង

៨/- ឧបត្ថម្ភជូន តំណាងមាតាបិតា និងប្រជាពលរដ្ឋ ចំនួន៣៥០នាក់ ក្នុងម្នាក់ទទួលបាន សារុង១ និងថវិកា ២០.០០០រៀល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលជាគណៈអធិបតី ព្រមទាំង លោកគ្រូ អ្នកគ្រូ មាតា បិតា ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងសូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***